រៀបចំដោយ

គាំទ្រដោយ

# ព្រឹត្តិបត្រពាណិជ្ជកម្ម
# iTrade Bulletin

## Inside

infographic

"ពាណិជ្ជកម្មអេឡិចត្រូនិកនៅកម្ពុជា៖ ការយល់ដឹង និងនិន្នាការទីផ្សារសំខាន់ៗ"

"Cambodia's E-commerce: Key Insights & Trends"


វ៉ុល ០១ | លេខ ០២ | ខែមីនា ឆ្នាំ២០២៥

VOLUME 01 | ISSUE 02 | MARCH 2025

# “ពាណិជ្ជកម្មអេឡិចត្រូនិកនៅកម្ពុជា៖ ការយល់ដឹង និងនិន្នាការទីផ្សារសំខាន់ៗ”

## កំណើនពាណិជ្ជកម្មអេឡិចត្រូនិកនៅកម្ពុជា

ទំហំទីផ្សារ៖ **១,៥១ ប៊ីលានដុល្លារ** (២០២៤) ដែលព្យាករណ៍ថានឹងឈានដល់ **១,៧៨ ប៊ីលានដុល្លារ**នៅឆ្នាំ(២០២៥)

- (២០២៤) **១,៥១ ប៊ីលានដុល្លារ**
- (២០២៥) **១,៧៨ ប៊ីលានដុល្លារ**

## អត្រាកំណើនប្រចាំឆ្នាំរួម

**១៧,៨៨% (២០២៤-២០២៥)**

## ចំណែកពាណិជ្ជកម្មអេឡិចត្រូនិកក្នុងទីផ្សារអាស៊ាន

កម្ពុជារួមចំណែក **១,៣%** ក្នុងទីផ្សារតំបន់ ដែលប្រាក់ចំណូលទីផ្សារពាណិជ្ជកម្មអេឡិចត្រូនិកអាស៊ានកើនដល់ **១១៦,៣៦ ប៊ីលានដុល្លារ**ក្នុងឆ្នាំ**២០២៤**

## កំណើនពាណិជ្ជកម្មអេឡិចត្រូនិករបស់អាស៊ាន

- (២០២៤) **១១៦,៣៦ ប៊ីលានដុល្លារ**
- (២០២៥) **១៣៧,២៤ ប៊ីលានដុល្លារ**

ទីផ្សារក្នុងតំបន់ត្រូវបានព្យាករណ៍នឹងកើនពី **១១៦,៣៦ ប៊ីលានដុល្លារ(២០២៤)** ដល់ **១៣៧,២៤ប៊ីលានដុល្លារ(២០២៥)** ប្រមាណ**១៧,៩៤%**

## ការចូលរួមចំណែកដល់ផសស

ពាណិជ្ជកម្មអេឡិចត្រូនិកបានរួមចំណែកពី**១,៥១ ប៊ីលានដុល្លារ (៦,៦៨%)** នៃផលិតផលក្នុងស្រុកសរុបរបស់កម្ពុជាក្នុងឆ្នាំ**២០២៤**

ពាណិជ្ជកម្មតាមបណ្តាញសង្គម៖ Facebook, TikTok, Telegram គ្របដណ្តប់ទីផ្សារអនឡាញ

## និន្នាការ និងទំនោរអ្នកប្រើប្រាស់

Facebook **(១១,៦៥ លានគណនី)** TikTok **(៩,៩៦ លានគណនី)**

ថ្នាលទិញទំនិញសំខាន់ៗ៖ Facebook (**១១,៦៥** លានគណនី), TikTok (**៩,៩៦** លានគណនី), Khmer 24, Taobao

ការទិញទំនិញជាប្រចាំ៖ អ្នកទិញភាគច្រើនចំណាយមួយដងក្នុងមួយខែចន្លោះ: **១១-៥០ដុល្លារ**

## បញ្ហាសំខាន់ៗ៖

- **២៣%** ការក្លែងបន្លំ
- **២០%** គុណភាពផលិតផល
- **១៤%** ថ្លៃដឹកជញ្ជូនខ្ពស់

## ការទិញតាមអនឡាញភាគច្រើន៖

- **៣៧%** ម៉ូដសម្លៀកបំពាក់
- **២០%** ថែរក្សាសម្រស់និងគ្រឿងសំអាង
- **១៩%** ការដឹកជញ្ជូនអាហារ

**ការទូទាត់ប្រាក់តាមប្រព័ន្ធបាគងមាន៖**
បាគង BAKONG
ចំនួន៥៤,៨ ប៊ីលានដុល្លារត្រឹមពាក់កណ្តាលឆ្នាំ ២០២៤

**កំណើននៃការទូទាត់តាមរយៈ QR កូដ៖**
ប្រតិបត្តិការចំនួន ៦០១,៣លាន ២០២៣

**ភ្នាក់ងារ KHQR៖**
KHQR
៣,៣លាននាក់ ២០២៣

ប្រភព៖ របាយការណ៍ពាណិជ្ជកម្មអេឡិចត្រូនិករបស់កម្ពុជាក្នុងឆ្នាំ២០២៤ រៀបចំដោយPROFITENCE

## វិធីទូទាត់ច្រើនជាងគេ

- ប្រព័ន្ធ QR កូដ: **៤៧,១៥%**
- សាច់ប្រាក់: **២៦,៥០%**
- ការផ្ទេរប្រាក់តាមទូរសព្ទ: **១៣,៣០%**
- និងផ្សេងៗ: **១៣,០៥%**

## សមាហរណកម្មធនាគារ៖

- ABA: **៤៦,៨៩%**
- **៣០,៩០%**
- Wing Bank: **១៧,០២%**
- ...: **៥,១៩%**

កំណើន នៃសេវាកម្មទិញឥឡូវ ទូទាត់ពេលក្រោយ (BNPL)៖ពង្រីកសកម្មភាពលក់រាយតាមអនឡាញ

## អ្នកប្រើប្រាស់ទូរសព្ទចល័តលើបណ្តាញសង្គមនៅកម្ពុជាក្នុងឆ្នាំ២០២៤

- ការចុះឈ្មោះប្រើប្រាស់ទូរសព្ទចល័ត **២១, ៩ លានគណនី**
- អ្នកប្រើប្រាស់ FACEBOOK **៩,៩៦ លានគណនី**
- ការចុះឈ្មោះប្រើប្រាស់អ៊ីនធឺណិត **២១,៩ លានគណនី**
- អ្នកប្រើប្រាស់ TIKTOK **១១,៦៥ លានគណនី**

## គំនិតផ្តួចផ្តើម និងបទប្បញ្ញត្តិរបស់រាជរដ្ឋាភិបាល

- ក្របខណ្ឌគតិយុត្តសម្រាប់វិញ្ញាបនបត្រសម្គាល់ទំនុកចិត្តពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- ការធ្វើសាមញ្ញកម្មការចុះបញ្ជីអាករលើតម្លៃបន្ថែមតាមប្រព័ន្ធអេឡិចត្រូនិក (សម្រាប់អាជីវកម្មបរទេស និងអាជីវកម្មក្នុងស្រុក)
- ផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍ជំនាញឌីជីថលនៅកម្ពុជា ២០២៤-២០៣៥
- ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥
- គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥
- គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨
- យុទ្ធសាស្ត្រពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- អនុក្រឹត្យស្តីពីការកំណត់ប្រភេទ បែបបទ និងនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណដល់អន្តរការីនិងបុគ្គលផ្តល់សេវាពាណិជ្ជកម្ម តាមប្រព័ន្ធអេឡិចត្រូនិក និងការលើកលែង
- ប្រកាសស្តីពី ការផ្តល់លិខិតអនុញ្ញាតឬអាជ្ញាបណ្ណពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក

**រៀបចំដោយ**

**គាំទ្រដោយ**

សូមស្កេនដើម្បីទាញយកព្រឹត្តបត្រពាណិជ្ជកម្ម

** ព័ត៌មានបន្ថែម
សូមទាក់ទងមកកាន់លេខទូរស័ព្ទទំនាក់ទំនងសាធារណៈ: **១២៦៦**

# "CAMBODIA'S E-COMMERCE
## KEY INSIGHTS & TRENDS"

## E-COMMERCE GROWTH IN CAMBODIA

(2024) 1.51 Billion

(2025) 1.78 Billion

MAKET SIZE: USD **1.51 billion (2024)**, projected to reach USD **1.78 billion (2025).**

## COMPOUND ANNUAL GROWTH RATE

(17.88% (2024-2025)

## ASEAN E-COMMERCE SHARE

Cambodia contributes **1.3%** to the regional market, which ASEAN E-Commerce market revenue is set to reach **116.36 billion** in **2024**

asean

## ASEAN E-COMMERCE GROWTH

(2024) $116.36 Billion

(2025) $137.24 Billion

The regional market is expected to grow by **17.94%** from **$116.36 billion (2024)** to **$137.24 billion (2025)**

## GDP CONTRIBUTION

E-commerce contributes **$1.51 billion (6.68%)** of Cambodia's GDP in **2024**

Social Commerce: Facebook, TikTok, Telegram dominate online sales

## CONSUMER TRENDS & PREFERENCES

(11.65 MILLION) (9.96 MILLION)

- Main Shopping Platforms: Facebook, TikTok, Khmer24, Taobao.
- Shopping Frequency: Majority shop once a month, spending **$11-$50/month.**

### TOP CONCERNS

- 23% Fraud
- 20% Product Quality
- 14% High Delivery Fees

### TOP ONLINE PURCHASES

- 37% Fashion
- 20% Beauty & Cosmetics
- 19% Food Delivery

| BAKONG PROCESSED | QR PAYMENTS GROWTH | KHQR MERCHANTS |
|---|---|---|
| $54.8 billion in H1 2024 | 601.3 million transactions 2023 | 3.3 million 2023 |

Source: Cambodia's E-commerce Report in 2024 prepared by PROFITENCE

## TOP PAYMENT METHODS

| Method | Share |
|---|---|
| QR CODES | 47.15% |
| CASH | 26.50% |
| MOBILE MONEY TRANSFER | 13.30% |
| AND OTHER | 13.05% |

## BANKING INTEGRATION

| Bank | Share |
|---|---|
| ABA | 46.89% |
| (bank logo) | 30.90% |
| Wing Bank | 17.02% |
| (other) | 5.19% |

•Rise of BNPL (Buy Now, Pay Later) Expanding with online retailers.

## INTERNET AND MOBILE CONSUMER ON SOCIAL NETWORK IN CAMBODIA IN 2024

- MOBILE SUBSCRIPTIONS **21.9 million**
- FACEBOOK ACCOUNT **9.96 million**
- INTERNET SUBSCRIPTIONS **21.9 million**
- TIKTOK ACCOUNT **11.65 million**

## GOVERNMENT INITIATIVES & REGULATIONS

- Legal Framework for E-commerce Trustmark
- Simplified E-commerce VAT Registration for foreign & local businesses
- Cambodia Digital Skill Development Roadmap 2024-2035
- Digital Economy and Society Policy Framework 2021-2035
- Cambodia Digital Government Policy 2022-2035
- Cambodia Financial Technology Development Policy 2023-2028
- E-Commerce Strategy
- Law on E-commerce
- Sub-decree on Determining the Types, Procedures for Granting Permit or License to Intermediaries and Individual Providing E-Commerce Services and Exemptions
- Prakas on Issuance of E-Commerce Licenses or Permit

## Organized by

## Supported by

**Scan to access iTrade Bulletin**

** For more imformation, please contact the Ministry of Commerce Call center **1266**

## ព្រះរាជាណាចក្រកម្ពុជា សន្យាគោរពតាមគោលការណ៍របស់អង្គការពាណិជ្ជកម្មពិភពលោក

លោកជំទាវ ចម និម្មល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានសម្តែងការគាំទ្រចំពោះប្រព័ន្ធពាណិជ្ជកម្មពហុភាគី នៃអង្គការពាណិជ្ជកម្មពិភពលោក ដោយបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការប្រកាន់ខ្ជាប់នូវគោលការណ៍របស់ខ្លួន និងការលើកកម្ពស់តម្លាភាពពាណិជ្ជកម្មសកល។ លោកជំទាវបានដឹកនាំគណៈប្រតិភូអន្តរក្រសួង ចូលរួមកិច្ចប្រជុំត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មលើកទី៣ ដែលត្រូវបានរៀបចំឡើងនៅទីស្នាក់ការអង្គការពាណិជ្ជកម្មពិភពលោក នៅប្រទេសស្វីស និងបានប្តេជ្ញាអនុវត្តតាមគោលការណ៍តម្លាភាព ដើម្បីផលប្រយោជន៍ទៅវិញទៅមក។ លោកជំទាវ ក៏បានចែករំលែកព័ត៌មានថ្មីៗ អំពីវឌ្ឍនភាព និងសមិទ្ធិផលសំខាន់ៗ ដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចបាន បន្ទាប់ពីកិច្ចប្រជុំត្រួតពិនិត្យគោលនយោបាយពាណិជ្ជកម្មលើកទី២ ជាពិសេសក្នុងវិស័យកំណើនសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការអភិវឌ្ឍវិនិយោគ។ *ប្រភព៖* *Khmer Times*

## កម្ពុជាត្រៀមទាញយកសក្តានុពលបញ្ញាសិប្បនិម្មិត (AI) ដើម្បីជំរុញកំណើនសេដ្ឋកិច្ច

កម្ពុជាកំពុងជំរុញកិច្ចខិតខំប្រឹងប្រែង ដើម្បីប្រើប្រាស់បញ្ញាសិប្បនិម្មិត សម្រាប់កំណើនសេដ្ឋកិច្ច ដោយធ្វើជាម្ចាស់ផ្ទះរៀបចំវេទិកាជាតិ ស្តីពីការត្រៀមខ្លួនទទួលយកបច្ចេកវិទ្យាបញ្ញាសិប្បនិម្មិតជាមួយ UN-ESCAP។ ព្រឹត្តិការណ៍នេះបានប្រមូលផ្តុំអ្នកចូលរួមប្រហែល២០០ នាក់ ដើម្បីពិភាក្សាអំពីវិធីសាស្ត្របង្រួម និងបរិយាបន្ន ចំពោះការអភិវឌ្ឍបញ្ញាសិប្បនិម្មិតដែលដឹកនាំដោយក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ យុទ្ធសាស្ត្រជាតិ ស្តីពីបញ្ញាសិប្បនិម្មិតដំណាក់កាលទី១ កំពុងស្ថិតក្នុងការអភិវឌ្ឍ ដោយផ្តោតលើផ្នែកសំខាន់ៗ ចំនួនប្រាំបី រួមមាន ផលិតភាព ការស្រាវជ្រាវ និងហេដ្ឋារចនាសម្ព័ន្ធឌីជីថល។ មន្ត្រីជំនាញ បានសង្កត់ធ្ងន់លើការប្រើប្រាស់បញ្ញាសិប្បនិម្មិតប្រកបដោយទំនួលខុសត្រូវ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធឱ្យស្របតាមគោលដៅអភិវឌ្ឍន៍។ បញ្ហាប្រឈមដូចជាក្រមសីលធម៌ និងផលបច្ច័យការងារត្រូវបានទទួលស្គាល់។ កម្ពុជាផ្តោតលើបញ្ញាសិប្បនិម្មិតជាកត្តាសំខាន់ សម្រាប់ជំរុញវឌ្ឍនភាពសេដ្ឋកិច្ច-សង្គម នាពេលអនាគត ស្របតាមការព្យាករណ៍ពីការរីកចម្រើនបញ្ញាសិប្បនិម្មិតក្នុងអាស៊ាន។ *ប្រភព៖* *Khmer Times*

## ការដាក់ឱ្យដំណើរការផ្លូវដឹកជញ្ជូន ខ្សែប្រវាក់ផ្គត់ផ្គង់ត្រជាក់ថ្មីកម្ពុជា-ចិន

ផ្លូវដឹកជញ្ជូន "ខ្សែប្រវាក់ផ្គត់ផ្គង់ត្រជាក់ និងទំនិញទូទៅ" ថ្មីពីកំពង់ផែ Fangchenggang របស់ចិន ទៅកាន់ខេត្តកោះកុង របស់កម្ពុជា ត្រូវបានដាក់ឱ្យដំណើរការកាលពីថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៥ ដើម្បីជំរុញការនាំចេញទំនិញកសិផលកម្ពុជា។ ការដឹកជញ្ជូនត្រង់ បានកាត់បន្ថយពេលវេលាដឹកជញ្ជូនជាង៥០% និងថ្លៃដឹកជញ្ជូនជាង២០% ដោយធានាបាននូវគុណភាពផលិតផល និងការប្រកួតប្រជែងកាន់តែប្រសើរ។ មន្ត្រី និង ធុរកិច្ចជនកម្ពុជារំពឹងថាផ្លូវដឹកជញ្ជូននេះ នឹងពង្រឹងទំនាក់ទំនងពាណិជ្ជកម្មជាមួយចិន ជាពិសេសក្នុងវិស័យសក្តានុពល កសិកម្ម និងឱសថ។ ក្នុងឆ្នាំ២០២៤ កម្ពុជាបាននាំចេញទំនិញកសិផលចំនួន១១,៧ លានតោន ប្រមាណ ៤,៨ប៊ីលានដុល្លារ។ ចិននៅតែជាដៃគូពាណិជ្ជកម្មធំបំផុតរបស់កម្ពុជា ដោយទំហំពាណិជ្ជកម្មទ្វេភាគីឈានដល់២,៦៦ ប៊ីលានដុល្លារ ក្នុងរយៈពេលពីរខែដំបូងនៃឆ្នាំ២០២៥។ *ប្រភព៖* *Khmer Times*

## អាស៊ានមានគោលបំណងក្លាយជាកំពូលសេដ្ឋកិច្ចទី៤ លើពិភពលោក

អាស៊ានមានគោលបំណងក្លាយជាមហាអំណាចសេដ្ឋកិច្ចទីបួនរបស់ពិភពលោកនៅឆ្នាំ២០៣០ ដោយការកសាងពាណិជ្ជកម្ម ការវិនិយោគ និងកិច្ចប្រឹងប្រែងធ្វើសមាហរណកម្មតំបន់ដ៏រឹងមាំ។ ឯកឧត្តម កៅ គឹមហួន អគ្គលេខាធិការអាស៊ាន បានលើកឡើងពីគោលដៅនេះ ក្នុងវេទិកាទស្សនៈវិស័យអាស៊ាននៅទីក្រុងភ្នំពេញ ដោយលើកឡើងពីទំហំពាណិជ្ជកម្មចំនួន ៣,៥ ទ្រីលានដុល្លារ និងការកើនឡើងនៃការវិនិយោគបរទេស ជាពិសេសពីចិន។ អាស៊ានក៏កំពុងជំរុញការស្តារឡើងវិញលើវិស័យទេសចរណ៍ ដោយមានភ្ញៀវទេសចរចំនួន១២៣ លាននាក់ក្នុងឆ្នាំ២០២៤។ ពាណិជ្ជកម្មរបស់កម្ពុជាបានកើនឡើងជិត២៥% ក្នុងខែមករា ឆ្នាំ២០២៥ ហើយផលិតផលក្នុងស្រុកសរុបត្រូវបានព្យាករណ៍ថានឹងកើនឡើង៦,៣% នៅឆ្នាំនេះ។ កត្តាជំរុញកំណើនសំខាន់ៗ រួមមាន វិស័យឧស្សាហកម្ម សេវាកម្ម និងទេសចរណ៍ ដោយសារអាស៊ានជំរុញហេដ្ឋារចនាសម្ព័ន្ធ បរិវត្តកម្មឌីជីថល និងការអភិវឌ្ឍប្រកបដោយចីរភាព ដើម្បីសម្រេចបាននូវគោលដៅដ៏ធំរបស់ខ្លួន។ *ប្រភព៖* *Khmer Times*

## Kingdom pledges to uphold WTO principles

Cham Nimul, Minister of Commerce (MoC), expressed support for the multilateral trading system of the World Trade Organization (WTO), reaffirming Cambodia's commitment to adhering to its principles and promoting global trade transparency. Leading the inter-ministerial delegation to attend the 3rd Trade Policy Review (TPR) meeting, held at the WTO headquarters in Switzerland, the MoC Minister committed to complying with the transparency principle for mutual benefits. The Minister also shared key updates on the progress and significant achievements the RGC has made since the 2nd TPR meeting, particularly in the areas of economic growth, trade and investment development.

***Source: Khmer Times***

## Cambodia Prepares to Reap AI Potential to Drive Economic Growth

Cambodia is advancing efforts to harness Artificial Intelligence (AI) for economic growth, hosting a national forum on AI readiness with UN-ESCAP. Led by NCSTI and MISTI, the event gathered around 200 participants to discuss a unified, inclusive approach to AI development. A first phase of national AI strategy is in progress, focusing on eight key areas including productivity, research, and digital infrastructure. Officials stressed responsible AI use, stakeholder collaboration, and alignment with development goals. Challenges like ethics and job impacts were acknowledged. Cambodia aims to position AI as a key driver for future socio-economic progress, aligning with ASEAN's projected AI-driven growth.

***Source: Khmer Times***

## New Sino-Cambodia 'Cold Chain' Shipping Route Launched

A new "cold chain + general cargo" shipping route from Fangchenggang, China, to Koh Kong, Cambodia, was launched on March 15, 2025 to boost agricultural exports. The direct route cuts shipping time by over 50% and reduces costs by more than 20%, ensuring better product quality and competitiveness. Cambodian officials and business leaders expect the route to strengthen trade ties with China, especially in agriculture and potentially pharmaceuticals. In 2024, Cambodia exported 11.7 million tonnes of agricultural products, worth $4.8 billion. China remains Cambodia's largest trade partner, with bilateral trade reaching $2.66 billion in the first two months of 2025.

***Source: Khmer Times***

## ASEAN Shooting for Top Four Global Economy Spot

ASEAN aims to become the world's fourth-largest economy by 2030, building on strong trade, investment, and regional integration efforts. Secretary-General Kao Kim Hourn highlighted this goal during the ASEAN Vision Forum in Phnom Penh, citing $3.5 trillion in trade and rising foreign investment, especially from China. ASEAN is also leveraging tourism recovery, with 123 million visitors in 2024. Cambodia's trade grew by nearly 25% in January 2025, and GDP is projected to rise 6.3% this year. Key growth drivers include industry, services, and tourism, as ASEAN pushes infrastructure, digital transformation, and sustainable development to reach its ambitious target.

***Source: Khmer Times***

## សហភាពអឺរ៉ុប និងឥណ្ឌាគ្រោងនឹងបញ្ចប់ការចរចារកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនៅចុងឆ្នាំនេះ

សហភាពអឺរ៉ុប និងឥណ្ឌាកំពុងធ្វើការឆ្ពោះទៅរកការចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាប្រវត្តិសាស្ត្រនៅចុងឆ្នាំ២០២៥នេះ ទោះបីជាការចរចាបានជាប់គាំងជាច្រើនឆ្នាំក៏ដោយ។ ប្រធានគណៈកម្មការអឺរ៉ុបបានបញ្ជាក់ពីពេលវេលាយ៉ាងច្បាស់នៅទីក្រុងញូវដែលី ដោយលើកឡើងពីភាពចាំបាច់នៃភូមិសាស្ត្រនយោបាយ សម្រាប់ទំនាក់ទំនងសេដ្ឋកិច្ចឱ្យកាន់តែរឹងមាំ។ សហភាពអឺរ៉ុបស្វែងរកច្រកចូលទៅកាន់ទីផ្សារឥណ្ឌាសម្រាប់រថយន្ត និងស្រា ខណៈដែលឥណ្ឌាមានការប្រុងប្រយ័ត្នចំពោះវិស័យកសិកម្ម និងគោលនយោបាយបៃតងរបស់សហភាពអឺរ៉ុបដូចជាយន្តការកែតម្រូវព្រំដែនកាបូន (CBAM)។ ជាមួយនឹងការគម្រាមកំហែងពន្ធរបស់លោកប្រធានាធិបតី ដូណាល់ ត្រាំ សហភាពអឺរ៉ុបកំពុងផ្តល់អាទិភាពដល់ប្រទេសឥណ្ឌាក្នុងការពង្រឹងភាពធន់នឹងពាណិជ្ជកម្ម។ ការចរចានៅតែមានភាពស្មុគស្មាញ ប៉ុន្តែភាគីទាំងពីរនៅតែប្តេជ្ញាចិត្តលើកិច្ចព្រមព្រៀងពាណិជ្ជកម្មនេះ។

*ប្រភព៖ EURONEWS*

## សហភាពអឺរ៉ុបចាត់វិធានការលើពន្ធគយ២៥% របស់លោកប្រធានាធិបតី ដូណាល់ ត្រាំលើដែក និងអាលុយមីញ៉ូម

ពន្ធគយចំនួន២៥% របស់លោកប្រធានាធិបតីអាម៉េរិក ដូណាល់ ត្រាំ លើការនាំចូលដែកថែប និងអាលុយមីញ៉ូមបានចូលជាធរមាននៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៥ ដែលបង្កឱ្យមានការតបតភ្លាមៗពីសហភាពអឺរ៉ុប។ សហភាពអឺរ៉ុបបានប្រកាសពីការតបតពន្ធគយលើទំនិញអាម៉េរិក ដែលមានតម្លៃ២៨,៣៣ ប៊ីលានដុល្លារ ដែលចាប់ផ្តើមនៅក្នុងខែមេសាខាងមុខ ដោយហៅវិធានការនេះថាជាការចាំបាច់ដើម្បីការពារអាជីវកម្ម និងកម្មករអឺរ៉ុប។ នាយករដ្ឋមន្ត្រីអូស្ត្រាលីលោក Anthony Albanese បានរិះគន់ពន្ធគយថា "មិនសមហេតុផល" ទោះបីជាអូស្ត្រាលីនឹងមិនដាក់វិធានការពន្ធ ដើម្បីជៀសវាងការកើនឡើងតម្លៃទំនិញដល់អ្នកប្រើប្រាស់។ ទន្ទឹមនឹងនេះ សហរដ្ឋអាម៉េរិកផ្អាកដំឡើងពន្ធដែលបានគ្រោងទុកដល់៥0% លើលោហៈរបស់កាណាដា បន្ទាប់ពីការសម្រេចចិត្តរបស់ក្រុង Ontario ក្នុងការយកពន្ធ២៥% លើថ្លៃអគ្គីសនីសម្រាប់ការនាំចេញទៅអាម៉េរិក។ *ប្រភព៖ CNBC*

## ការព្យាករណ៍សេដ្ឋកិច្ចសកលមិនច្បាស់លាស់ចំពេលមានកំណើនយឺត និងភាពតានតឹងពាណិជ្ជកម្ម

ការព្យាករណ៍សេដ្ឋកិច្ចបណ្តោះអាសន្នរបស់អង្គការសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) ព្រមានពីភាពយឺតយ៉ាវនៃកំណើនសេដ្ឋកិច្ចពិភពលោក អតិផរណានៅបន្តស្ថិតនៅកម្រិតខ្ពស់ ជាមួយនឹងភាពមិនច្បាស់លាស់នៃគោលនយោបាយពាណិជ្ជកម្ម។ ផលិតផលក្នុងស្រុកសរុបសកលត្រូវបានព្យាករណ៍ថានឹងធ្លាក់ចុះមកត្រឹម៣,១% នៅឆ្នាំ២០២៥ និង ៣% នៅឆ្នាំ២០២៦ ជាមួយនឹងកំណើនសេដ្ឋកិច្ចអាម៉េរិកនៅ២,២% ក្នុងឆ្នាំ២០២៥ ធ្លាក់ចុះមកត្រឹម១,៦%, តំបន់អឺរ៉ុបពី ១% ទៅ ១,២% ហើយចិននឹងធ្លាក់ចុះមកត្រឹម៤,៤%។ អតិផរណានៅតែខ្ពស់ដដែល ដោយអតិផរណារបស់ក្រុមប្រទេសG20 ត្រូវបានគេព្យាករណ៍ថានឹងមានកម្រិត៣,៨% ក្នុងឆ្នាំ២០២៥។ OECD បង្ហាញពីហានិភ័យពីការបែងខ្ញែកពាណិជ្ជកម្ម ភាពមិនច្បាស់លាស់នៃគោលនយោបាយ និងកម្រិតបំណុលខ្ពស់។ OECD ជំរុញឱ្យមានការពង្រឹងច្បាប់សារពើពន្ធ កំណែទម្រង់រចនាសម្ព័ន្ធ និងការប្រើប្រាស់បញ្ញាសិប្បនិម្មិត ដើម្បីជំរុញផលិតភាព និងស្ថិរភាពទីផ្សារចំពេលមានការកើនឡើងនៃបញ្ហាប្រឈមជាសកល។

*ប្រភព: OECD*

## ចិនបង្ហាញផែនការជំរុញការប្រើប្រាស់ ចំពេលដែលការដំឡើងពន្ធរបស់លោកប្រធានាធិបតី ដូណាល់ ត្រាំ

ចិនបានប្រកាស "ផែនការសកម្មភាពពិសេស" ដ៏ធំទូលាយមួយ ដើម្បីជំរុញការចំណាយក្នុងស្រុក ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីទប់ទល់នឹងផលប៉ះពាល់សេដ្ឋកិច្ចនៃការដំឡើងពន្ធគយដែលដាក់ដោយលោកប្រធានាធិបតី ដូណាល់ ត្រាំ។ ផែនការនេះគ្របដណ្តប់អ្វីៗគ្រប់យ៉ាងចាប់ពីការជំរុញប្រាក់ចំណូលរបស់ប្រជាជន ដល់ការបង្កើតប្រព័ន្ធឧបត្ថម្ភធនសម្រាប់ការថែទាំកុមារ និងការពង្រីកកម្មវិធី "ការទទួលបានការឧបត្ថម្ភសាច់ប្រាក់" ដើម្បីដោះដូរទំនិញចាស់ៗ ដូចជារថយន្ត និងគ្រឿងអេឡិចត្រូនិចជាដើម។ ឯកឧត្តម Li Qiang នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាមានិតចិនបានកំណត់គោលដៅកំណើនខ្ពស់ "ប្រហែល ៥%" សម្រាប់ឆ្នាំនេះ។ កំណើននេះអាចទៅរួចតាមរយៈការជំរុញការចំណាយ ដើម្បីធានាថា ចិនមិនចាំបាច់ពឹងផ្អែកលើការនាំចេញដើម្បីផ្តល់ថាមពលដល់សេដ្ឋកិច្ចដ៏ធំរបស់ខ្លួន ដែលកំពុងមានកំណើនយឺត។ លោកប្រធានាធិបតី ត្រាំ បានដំឡើងពន្ធទ្វេដង

លើការនាំចូលរបស់ចិនទាំងអស់ដល់២០% គិតត្រឹមខែនេះ។ ជាការឆ្លើយតប ចិនបានប្រកាសអំពីការដំឡើងពន្ធតបតថ្មី ដោយគ្របដណ្តប់លើការនាំចូលផលិតផលកសិកម្មរបស់អាម៉េរិក ដែលបានចូលជាធរមានកាលពីសប្តាហ៍មុន។ *ប្រភព៖ CNN*

### ឯកឧត្តម Scott Bessent រដ្ឋមន្ត្រីរតនាគារជាតិអាម៉េរិក៖ 'ខ្ញុំមិនអាចធានាបានទេ' អាម៉េរិកនឹងជៀសផុតពីវិបត្តិសេដ្ឋកិច្ច

ទីផ្សារភាគហ៊ុន Wall Street បានធ្លាក់ចុះកាលពីសប្តាហ៍មុនបន្ទាប់ពីលោកប្រធានាធិបតី ដូណាល់ ត្រាំ បាននិយាយថា គាត់មិនបានប្រានចោលវិបត្តិសេដ្ឋកិច្ចទេ ហើយថាប្រជាជនអាម៉េរិកគួរតែរំពឹងថានឹងមាន "រយៈពេលអន្តរកាល" សេដ្ឋកិច្ចទាំងមូល។ សេដ្ឋវិទូរបស់ JPMorgan បានកំណត់លទ្ធភាព៤០% ដែលសេដ្ឋកិច្ចអាម៉េរិកធ្លាក់ចូលក្នុងវិបត្តិសេដ្ឋកិច្ច ដែលជាការកើនឡើង១០% ធៀបនឹងដើមឆ្នាំនេះ។ ការកែសម្រួលនេះ ដោយសារតែការបង្កើនពន្ធគយ ដែលសេដ្ឋវិទូរបស់ធនាគារចាត់ទុកថា ការបង្កើនពន្ធគយនេះនឹងកាត់បន្ថយសកម្មភាពអាជីវកម្មរហូតដល់ចំណុចដែលវា "ធ្វើឱ្យសេដ្ឋកិច្ចអាម៉េរិក និងសេដ្ឋកិច្ចសកលធ្លាក់ក្នុងវិបត្តិសេដ្ឋកិច្ច"។ ការស្ទង់មតិថ្មីៗនេះបានបង្ហាញថា អាជីវកម្មកំពុងពន្យារពេលការវិនិយោគ និងមើលឃើញការថយចុះនៃប្រាក់ចំណូល នៅពេលដែលអតិថិជនបានកាត់បន្ថយការទិញដែលមួយផ្នែកដោយសារតែពន្ធនាំចូល។ *ប្រភព៖ CNN*

### អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍ (OECD) ថ្លែងថា ពន្ធគយរបស់លោកប្រធានាធិបតី ដូណាល់ ត្រាំ កំពុងធ្វើឱ្យខូចខាតសេដ្ឋកិច្ចធ្ងន់ធ្ងរ និងអតិផរណាបន្តកើនឡើង

ក្រុមប្រទេសអ្នកមាន៣៨ ដែលភាគច្រើនបានធ្វើការព្យាករណ៍សេដ្ឋកិច្ចជាថ្មី បង្ហាញអំពីស្ថានភាពសេដ្ឋកិច្ចកាន់តែអាក្រក់ជាងការព្យាករណ៍ពីមុន។ អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍបានព្យាករណ៍ថា កំណើនសេដ្ឋកិច្ចអាម៉េរិកនឹងធ្លាក់ចុះយ៉ាងខ្លាំងនៅឆ្នាំនេះ និងឆ្នាំក្រោយមកត្រឹម២,២% ក្នុងឆ្នាំ២០២៥ និងត្រឹមតែ១,៦% ក្នុងឆ្នាំ២០២៦។ សេដ្ឋកិច្ចរបស់អាម៉េរិកបានកើនឡើងក្នុងអត្រា២,៨% កាលពីឆ្នាំមុន។ សេដ្ឋកិច្ចពិភពលោកត្រូវបានគេរំពឹងថានឹងកើនឡើង ៣,១% នៅឆ្នាំនេះ និង៣% នៅឆ្នាំក្រោយ ធ្លាក់ចុះពី៣,២% ក្នុងឆ្នាំ២០២៤។ ទន្ទឹមនឹងនេះ អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការអភិវឌ្ឍបានព្យាករណ៍ថា អតិផរណារបស់អាម៉េរិកនឹងកើនឡើងនៅឆ្នាំនេះ។ តម្លៃទំនិញត្រូវបានគេរំពឹងថានឹងកើនឡើងពី២,៥% នៅឆ្នាំ២០២៤ ទៅ២,៨% នៅឆ្នាំ២០២៥ ហើយនឹងបន្តកើនឡើងប្រមាណ២,៦% នៅឆ្នាំ២០២៦ ផងដែរ។ *ប្រភព៖ CNN*

## EU And India Aim to Finalize Free Trade Agreement by Year-End

The European Union (EU) and India are working towards signing a historic free trade agreement (FTA) by the end of 2025, despite years of stalled negotiations. European Commission President confirmed the ambitious timeline in New Delhi, citing the geopolitical need for stronger economic ties. The EU seeks greater access to India's market for cars and spirits, while India is cautious about agriculture and EU green policies like CBAM. With Donald Trump's tariff threats looming, the EU is prioritizing India to strengthen trade resilience. Tough negotiations lie ahead, but both sides remain determined.
***Source: EURONEWS***

## Trump's 25% Tariffs on Steel and Aluminum Take Effect, EU Retaliates

U.S. President Donald Trump's 25% tariffs on steel and aluminum imports took effect on 19 March 2025, sparking immediate retaliation from the European Union (EU). The EU announced counter-tariffs on $28.33 billion worth of U.S. goods starting in April, calling the move necessary to protect European businesses and workers. Australia's Prime Minister Anthony Albanese criticized the tariffs as "entirely unjustified," though Australia will not impose retaliatory tariffs to avoid higher consumer prices. Meanwhile, the U.S. reversed a planned increase to 50% tariffs on Canadian metals, following Ontario's decision to pause its 25% electricity tax on U.S. exports.
***Source: CNBC***

## Global Economic Outlook Uncertain Amid Slower Growth and Trade Tensions

The OECD's Interim Economic Outlook warns of slower global growth, persistent inflation, and trade policy uncertainties. Global GDP is projected to slow to 3.1% in 2025 and 3.0% in 2026, with U.S. growth at 2.2% in 2025, falling to 1.6%, Eurozone at 1.0% to 1.2%, and China declining to 4.4%. Inflation remains high, with G20 headline inflation forecasted at 3.8% in 2025. The OECD highlights risks from trade fragmentation, policy uncertainty, and high debt levels. It urges fiscal discipline, structural reforms, and AI adoption to drive productivity and stabilize markets amid growing global challenges. ***Source: OECD***

## China Unveils Plan to Boost Consumption as Trump Tariffs Bite

China has announced a wide-ranging "special action plan" to promote domestic spending, in an effort to counter the economic impact of tariffs imposed by US President Donald Trump. It covered everything from boosting people's incomes to establishing a childcare subsidy system and expanding a "cash-for-clunkers" program to trade in old goods like cars and electronics. Li Qiang, Premier of the People's Republic of China, set an ambitious growth target of "around 5%" for this year. That would be possible only by boosting spending, to ensure China doesn't need to rely on exports to power its vast but slowing economy. Trump doubled tariffs on all Chinese imports to 20% as of this month. In response, China has announced a fresh round of retaliatory tariffs, covering US agriculture imports, which took effect last week. ***Source: CNN***

## Scott Bessent, US Treasury Secretary: 'I Can't Guarantee' America Will Avoid a Recession

Wall Street plunged last week after President Donald Trump said he was not ruling out a recession and that Americans should expect "a period of transition" across the economy. JPMorgan economists penciled in a 40% chance the US economy enters a recession, a 10 percentage point increase from earlier this year. The revision resulted from ramped-up tariffs that the bank's economists view as capable of putting a substantial drag on business activity to the point that it "throws the US economy and global economy into a recession." Recent surveys indicated that businesses are delaying investments and seeing revenue decline as customers put off purchases, in part due to tariffs.
***Source: CNN***

## Trump's Tariffs Are Inflicting Serious Economic Damage and Reigniting Inflation, OECD Says

The group of 38 mostly wealthy nations made new economic forecasts that are noticeably worse than its previous predictions. The OECD predicted US economic growth would slow dramatically this year and next, to 2.2% in 2025 and just 1.6% in 2026. America's economy grew at a 2.8% rate last year. The global economy is expected to grow 3.1% this year and 3% next year, down from 3.2% growth in 2024. Meanwhile, US inflation will pick up this year, the OECD predicted. Prices are expected to rise 2.8% in 2025, up from 2.5% last year. They'll continue to be elevated in 2026, rising 2.6%. ***Source: CNN***

# About the iTrade

iTrade Bulletin is an e-publication by the Trade Training and Research Institute of the Ministry of Commerce. This monthly bulletin provides brief updates on specific issues in Cambodia, the regions and the world.

This knowledge-sharing through scientific researches in the multifaceted areas aims to highlight current trade news & statistics relevant to all social stakeholders.


## Honorable President

H.E. Mrs. CHAM Nimul

## Editorial Board

- H.E. Dr. TAT Puthsodary (Chairman)
- H.E. Ms. SEREI Borapich
- Mr. HOR lengchhay
- Ms. PHAL Yita

## Advisor

- H.E. Mr. PENN Sovicheat
- H.E. Prof. Shandre Mugan THANGAVELU

## Teamwork

- Mr. PAO Phireak
- Ms. YANGNY Chakriya
- Mr. LY Rithy



## Special Thanks

- H.E. Mrs. CHEA Ratha
- Department of Legal Affairs
- Department of International Cooperation


## Announcement

Academicians, researchers, students and public are welcome to contribute their academic works, on all disciplines and topics of relevant interest to trade, to the next publication of the iTrade Bulletin.

## Topics Covered:

- International trade and logistics / trade laws;
- Digital economy / e-commerce;
- Economics and economic laws;
- Value added supply chains and logistics; and
- Facilitate the green business transition

## Categories:

- Research articles
- Case reports
- Policy Briefs


## Trade Training and Research Institute

Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA

ttri.moc | www.ttri.moc.gov.kh | @ttrimoccambodia